**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៤៩. សសរ**

# សេចក្តីសម្រេច

## ស្តីពី

## ការកែសម្រួលសមាសភាពគណៈកម្មការជំរុញការអនុវត្តគម្រោងអភិវឌ្ឍន៍ផ្លូវដែក និង សម្របសម្រួលរវាងគម្រោងអភិវឌ្ឍន៍ផ្លូវដែក និងគម្រោងអភិវឌ្ឍន៍បឹងកក់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រ កម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៧ ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសម្បទាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២១០/០០៣ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអស្សាមិករណ៍
- បានឃើញអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ដែលបានចុះហត្ថលេខា នៅថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៧
- បានឃើញសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការជំរុញការអនុវត្តគម្រោងអភិវឌ្ឍន៍ផ្លូវដែក និងសម្របសម្រួលរវាងគម្រោងអភិវឌ្ឍន៍ផ្លូវដែក និងគម្រោងអភិវឌ្ឍន៍បឹងកក់ ដែលបានចុះហត្ថលេខា នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

www.pheakdeylaw.com

**សម្រេច**

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មការជំរុញការអនុវត្តគម្រោងអភិវឌ្ឍន៍ផ្លូវដែក និងសម្របសម្រួលរវាងគម្រោងអភិវឌ្ឍន៍ផ្លូវដែក និងគម្រោងអភិវឌ្ឍន៍បឹងកក់ ដែលមានសមាសភាព ដូចខាងក្រោម:

| | | |
|---|---|---|
| ១- | ឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រីប្រចាំការ | ប្រធាន |
| ២- | ឯកឧត្តម **ត្រាំ អ៊ីវតឹក** រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន | អនុប្រធាន |
| ៣- | ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | អនុប្រធាន |
| ៤- | ឯកឧត្តម **វង្សី វិស្សុត** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ៥- | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៦- | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៧- | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | សមាជិក |
| ៨- | ឯកឧត្តម **ញាណ ឡេង** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ៩- | ឯកឧត្តម **អ៊ួន សុខ** អនុរដ្ឋលេខាធិការក្រសួងសាធារណការ និង ដឹកជញ្ជូន | សមាជិក |
| ១០- | ឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ | សមាជិក |
| ១១- | ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ | សមាជិក |
| ១២- | ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង | សមាជិក |
| ១៣- | ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តពោធិសាត់ | សមាជិក |
| ១៤- | ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង | សមាជិក |
| ១៥- | ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ | សមាជិក |
| ១៦- | ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តកណ្តាល | សមាជិក |
| ១៧- | ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តតាកែវ | សមាជិក |
| ១៨- | ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តកែប | សមាជិក |
| ១៩- | ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តកំពត | សមាជិក |
| ១២- | ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ | សមាជិក |

**ប្រការ ២.-**

គណៈកម្មការជំរុញការអនុវត្តគម្រោងអភិវឌ្ឍន៍ផ្លូវដែក និងសម្របសម្រួលរវាងគម្រោងអភិវឌ្ឍន៍ផ្លូវដែក និងគម្រោងអភិវឌ្ឍន៍បឹងកក់ មានភារកិច្ចដូចខាងក្រោម:

- ជំរុញការអនុវត្តគម្រោងស្តារឡើងវិញផ្លូវដែកទាំងពីរទិសរបស់កម្ពុជា ពីភ្នំពេញ-ក្រុងព្រះសីហនុ និង ភ្នំពេញ-ប៉ោយប៉ែត ក្រោមហិរញ្ញប្បទានសហប្រតិបត្តិការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ទីភ្នាក់ងារផ្តល់ជំនួយរបស់ប្រទេសអូស្ត្រាលីសម្រាប់ការអភិវឌ្ឍអន្តរជាតិ (AusAID) និងមូលនិធិ OPEC សម្រាប់ការអភិវឌ្ឍអន្តរជាតិឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត ។
- ជំរុញដាក់ចេញនូវវិធានការចាំបាច់នានា ដើម្បីដោះស្រាយរាល់ការងារ និងបញ្ហាដែលពាក់ព័ន្ធនឹងការស្តារឡើងវិញផ្លូវដែកកម្ពុជា ។

- ជំរុញប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអនុវត្តកិច្ចសន្យាសម្បទានផ្លូវដែក។
- សម្របសម្រួលរវាងការអនុវត្តគម្រោងអភិវឌ្ឍន៍ផ្លូវដែក និងគម្រោងអភិវឌ្ឍន៍បឹងកក់ ឱ្យមានដំណើរការទៅមុខ ដោយរលូនជាមួយគ្នា និងជួយបំពេញឱ្យគ្នាទៅវិញទៅមក ព្រមទាំងដោះស្រាយរាល់បញ្ហានានា ដែលអាចនឹងកើតមានឡើងជាយថាហេតុ។

**ប្រការ ៣.-**

គណៈកម្មការជំរុញការអនុវត្តគម្រោងអភិវឌ្ឍន៍ផ្លូវដែក និងសម្របសម្រួលរវាងគម្រោងអភិវឌ្ឍន៍ផ្លូវដែក និងគម្រោងអភិវឌ្ឍន៍បឹងកក់ មានសិទ្ធិបង្កើតអនុគណៈកម្មការបច្ចេកទេសមួយចំនួនជាជំនួយការតាមការចាំបាច់ និងមានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងក្រុមហ៊ុនសម្បទានផ្លូវដែក និងក្រុមហ៊ុនអភិវឌ្ឍន៍គម្រោងបឹងកក់ ចូលរួមការប្រជុំរបស់ខ្លួន ក្នុងករណីចាំបាច់។

**ប្រការ ៤.-**

អនុប្រធាន សមាជិក ត្រូវចូលរួមការប្រជុំ តាមការអញ្ជើញរបស់ប្រធាន។ ប្រធានអាចផ្ទេរសិទ្ធិជូនអនុប្រធានណាម្នាក់ ដើម្បីដឹកនាំការងារជំនួស ក្នុងករណីមានធុរៈជាយថាហេតុ។

**ប្រការ ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិតឧបនាយករដ្ឋមន្ត្រីប្រចាំការ
-ដូចប្រការ ៦
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

www.pheakdeylaw.com